# ការណែនាំមុនពេលដាក់ពាក្យសុំ

## ១. របៀបនៃការដាក់ពាក្យសុំ

- សូមអានសេចក្តីណែនាំនៃការដាក់ពាក្យអាហារូបករណ៍ឱ្យបានលម្អិតមុនពេលដាក់ពាក្យសុំ ។
- សូមរៀបចំដាក់ពាក្យសុំក្នុងស្រោមសំបុត្រពណ៌គគីរ(សីមី) ហើយបិទអោយជិត បង្ការការជ្រុះឯកសារចេញក្រៅ ព្រមទាំងសូមសរសេរឈ្មោះកម្រិតនៃការដាក់ពាក្យសុំ ឈ្មោះសាម៉ីខ្លួន និងលេខទូរសព្ទឱ្យបានត្រឹមត្រូវ។
- ច្បាប់ចំលងនៃអត្តសញ្ញាណបណ្ណ ឬកាតសម្គាល់ខ្លួន ព្រឹត្តិបត្តិពិន្ទុ ឬសៀវភៅសិក្ខាគារិក ឬសៀវភៅតាមដានជាភាសាខ្មែរពុំចាំបាច់ភ្ជាប់មកជាមួយនូវច្បាប់បកប្រែនោះឡើយ។
- សូមដាក់ពាក្យសុំទៅក្នុងប្រអប់ដែលបានរៀបចំនៅទីតាំងទទួលពាក្យសុំទៅតាមប្រភេទអាហារូបករណ៍នៃពាក្យសុំរបស់អ្នក ហើយបំពេញឈ្មោះក្នុងបញ្ជីពាក្យសុំ។
- សូមរួសរាន់ចាកចេញពីទីតាំងទទួលពាក្យសុំ បន្ទាប់ពីដាក់ពាក្យសុំ និងបំពេញឈ្មោះរួច ដើម្បីចៀសវាងការកកស្ទះ។

## ២. កំណត់ចំណាំ

- ប្រសិនបើអ្នកមកដោយយានយន្ត សូមចូលមកចតនៅក្នុងចំណតក្នុងស្ថានទូតជប៉ុនតាមការណែនាំរបស់សន្តិសុខ។
- ដោយសារស្ថានទូតមានច្រកចូលច្រើន ដូច្នេះសូមចូលតាមទ្វារកុងស៊ុលរបស់ស្ថានទូតជប៉ុន។
- សូមភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន ឬកាតសិស្ស និងធ្វើទៅតាមការណែនាំផ្សេងៗរបស់ផ្នែកសន្តិសុខពេលយកពាក្យសុំមកដាក់នៅស្ថានទូត។
- ពាក្យដែលដាក់ហើយមិនអាចដកវិញ ឬដាក់ម្តងទៀតបានទេ។ សូមពិនិត្យឱ្យបានម៉ត់ចត់ជៀសវាងកំហុសដោយប្រការណាមួយ។
- សូមកុំប៉ះពាល់ ឬមើលពាក្យសុំរបស់អ្នកដទៃ។
- ម៉ោងទទួលពាក្យ៖ **ចន្ទ ដល់ សុក្រ ០៨:៣០ ～១៦:០០** ។

## ៣. ផែនទីទីតាំងទទួលពាក្យសុំ

